# ពិធីប្រកាសតែងតាំងអនុរដ្ឋលេខាធិការថ្មីមួយរូបទៀតរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍



ពិធីប្រកាសតែងតាំងអនុរដ្ឋលេខាធិការមួយរូបទៀតគឺលោកជំទាវ **រស់ សុរក្ខា**របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានប្រព្រឹត្តទៅកាលពីថ្ងៃទី៧ ខែ ឧសភា ឆ្នាំ២០០៩ នៅទីស្តីការក្រសួង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **សូរ ឃុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤០១ចុះថ្ងៃទី១០ ខែមេសាឆ្នាំ២០០៩របស់ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** បានត្រាស់បង្គាប់តែងតាំងលោកជំទាវ **រស់ សុរក្ខា** អតីតអគ្គនាយកដ្ឋានរដ្ឋបាលជាអនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

នៅក្នុងឱកាសនោះ ឯកឧត្តមរដ្ឋមន្ត្រី **សូរ ឃុន** បានមានប្រសាសន៍ថា ការតែងតាំងលោកជំទាវ **រស់ សុរក្ខា** ជាអនុរដ្ឋលេខាធិការនេះ គឺជាផ្នែកមួយនៃការលើកកំពស់បញ្ហាយេនឌ័រនៅក្នុងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ផងដែរ។ ឯកឧត្តមរដ្ឋមន្ត្រីបានបន្តថា ការតែងតាំងនេះ គឺជាការលំបាកមួយ ហើយការបំពេញភារកិច្ចធ្វើជាថ្នាក់ដឹកនាំក៏ជាការលំបាកមួយដែរ ហើយអ្វីដែលលំបាកបំផុតនោះ គឺថា តើត្រូវធ្វើបែបណាខ្លះ ដើម្បីឱ្យអ្នកដែលនៅក្រោមបង្គាប់ គេស្តាប់ និងធ្វើតាមការណែនាំរបស់យើង ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយចុះ ភារកិច្ចដែលអាចធ្វើទៅបាន គឺវាអាស្រ័យលើការប្តេជ្ញាចិត្ត។

ឯកឧត្តមរដ្ឋមន្ត្រី **សូរ ឃុន** បានណែនាំកុំឱ្យណែនាំម្នាក់ៗប្រកាន់ឫកពារតឹងតែងបង្កផលលំបាកឱ្យមនុស្សក្រោមបង្គាប់ពិបាករកជួបពិភាក្សា ពីព្រោះថា ការស្វែងរកជួបរបស់មនុស្សក្រោមបង្គាប់ គឺជាការធ្វើតាមថ្នាក់ដឹកនាំ ហើយរូបឯកឧត្តមផ្ទាល់ក៏បានអនុវត្តដូចនេះដែរ គឺមិនទំលាប់ធ្វើឱ្យមនុស្សក្រោមបង្គាប់ពិបាកក្នុងការ

រកជួបលោកនោះឡើយ ។





ដោយឡែកចំពោះលោកជំទាវ **រស់ សូរភ្វា** វិញក៏បានឡើងប្តេជ្ញាចិត្តថា នឹងខិតខំបំពេញភារកិច្ចឱ្យអស់ពីកំលាំងកាយចិត្ត ដើម្បីឱ្យសក្តិសមទៅតាមការទទួលតំណែងជាអនុរដ្ឋលេខាធិការនៅក្នុងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នេះ ។ លោកជំទាវអនុរដ្ឋលេខាធិការថ្មីបានបន្តទៀតថា លោកជំទាវនឹងទទួលយកការណែនាំគ្រប់ចំណុច និងគ្រប់ពេលវេលាពីថ្នាក់ដឹកនាំនៅក្នុងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាពិសេស គឺពីឯកឧត្តម **សូរ ឃុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ជាទីគោរពតែម្តង ។



